ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០១៤

នៅក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចាត់ចែងរៀបចំទីកន្លែងសំរាប់ជំនួបក្រុមការងារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្ស សម រង្ស៊ី ដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងបានបំពេញការងារយ៉ាងសកម្មលើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការរៀបចំប្រជុំគណៈកម្មការពិសេស គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គលើកទី៥ ដំណើរការនីតិវិធីច្បាប់គម្រោងថវិកាឆ្នាំ២០១៥ ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើនការសន្សំសំចៃខ្ពស់ បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំប្រជុំគណៈកម្មការពិសេស គណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០១លើក សិក្ខាសាលា ស្តីពីការលើកកម្ពស់ការប្រាស្រ័យទាក់ទងរវាងសភា និងប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធិភាព ធ្វើតេស្តមន្ត្រីរាជការត្រៀមតាំងស៊ប់ក្នុងមុខតំណែង និងប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ចូលរួមក្នុងជំនួបសម្តែងការគួរសមរវាង ឯកឧត្តមសាយ **ឈុំ** អនុប្រធានទី១ព្រឹទ្ធសភា ជាមួយ ឯកឧត្តម Azuma KOS HISHI អនុប្រធានទី១ ព្រឹទ្ធសភាជប៉ុន និងឯកឧត្តម **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា ជួបជាមួយឯកឧត្តម Naoto Sakaguchi សមាជិក រដ្ឋសភាជប៉ុន និងឯកឧត្តម Kumamaru Yuji ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសជប៉ុន ចូលរួមកិច្ចប្រជុំរបស់សមាគមអគ្គលេខាធិការសភាពិភពលោក ស្តីពីគោលការណ៍រួមសម្រាប់អភិវឌ្ឍន៍សភា នៅប្រទេសហ្វីលីពីន (ការរៀបចំរួមរវាងព្រឹទ្ធសភាហ្វីលីពីន និង IPU ) និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន៥៥៣ច្បាប់ ។

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០២លើក ដើម្បី៖ ពិនិត្យ និងសម្រេចបង្កើតគណៈកម្មការពិសេស ដើម្បីពិនិត្យសិក្សាលើសំណើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការពិសេស សុំដាក់សេចក្តីស្នើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣ ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយតំណាងព្រឹទ្ធសភា កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៥ព្រឹទ្ធសភា

-រៀបចំប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០១លើក ដើម្បី៖ ពិនិត្យ និងសម្រេចលើសេចក្តីស្នើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ៖**

-បានចុះបំពេញការងារអមជាមួយគណៈកម្មការទី៨ របស់ព្រឹទ្ធសភា ក្នុងជំនួបសវនាការជាមួយមន្ត្រីជំនាញ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាត្រៀមរៀបចំសិក្ខាសាលាស្តីពីប្រព័ន្ធប្រលងប្រណាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការលើកកម្ពស់សមត្ថភាព និងការធ្វើទស្សនកិច្ច នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈមួយចំនួនក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-បញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយបាន ចំនួន០៥ករណី តម្កល់ទុកមិនចាត់ការចំនួន០១ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងចំនួន០២ករណី និងធ្វើលិខិតជំរុញការដោះស្រាយពាក្យបណ្តឹងទៅក្រសួងស្ថាប័នពាក់ព័ន្ធចំនួន០២ករណី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្តរាជធានីទូទាំងប្រទេសចំនួន៦៨លើក ដើម្បីចុះជួប និងជួយប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៣៩លើក ។

**៤.សេវាទ្រទ្រង់មុខងារព័ត៌មាន៖**

-មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មចំនួន០៧លើក ដើម្បី

សិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ត្រៀមរៀបចំវេទិកា ពិភាក្សាការងារជាមួយគណៈអភិបាលខេត្ត និងនាយករដ្ឋបាលសាលាខេត្ត និងចូលរួមសិក្ខាសាលា ស្តីពីការឆ្លុះបញ្ចាំងភាព ជាដៃគូក្នុងការបើកចំហព័ត៌មានជាសាធារណៈ និងដំណើរឆ្ពោះទៅរកអភិបាលកិច្ចល្អនៅខេត្តស្វាយរៀង កំពង់ឆ្នាំង ប៉ៃលិន ព្រៃវែង កំពង់ធំ និងខេត្តព្រះវិហារ ។

**៥.ការងារអន្តរជាតិ៖**

-ទទួលជួបជាមួយលេខាទី១ ស្ថានទូតជប៉ុន ។

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ APA ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌ នៅសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ និងទៅបំពេញទស្សនកិច្ចនៅសភាប្រឹក្សានយោបាយប្រជាមានិតចិន (CPPCC) នៅប្រទេសចិន ។

-រៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅចូលរួមសិក្ខាសាលា ស្តីពីការគ្រប់គ្រង និងលើកកម្ពស់មណ្ឌលព័ត៌មានសភា និងចូលរួមកិច្ចប្រជុំ IFLA World Library and Information Congress នៅប្រទេសបារាំង ចូលរួមមហាសន្និបាតលើកទី១៦ ក្រោមប្រធានបទ "សហគមន៍អាស៊ាន២០១៥ ដំណើរឆ្ពោះទៅមុខរបស់អង្គការសម្ព័ន្ធស្ត្រីអាស៊ាន" នៅប្រទេសម៉ាឡេស៊ី ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប៊្រុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ពានកុងស៊ុលបែលហ្សិក ស្ពានកុងស៊ុលន័រវ៉េស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center សាកលវិទ្យាល័យមេគង្គកម្ពុជា សាកលវិទ្យាល័យន័រតុន និងចំរើនពហុបច្ចេកវិទ្យា ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៣៦១នាក់ និងទស្សនកិច្ចសិក្សារបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ និងតំណាងសហគមន៍មកពីខេត្តកំពង់ឆ្នាំងចំនួន ៥៥នាក់ ។

**៧.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០២វគ្គ ស្តីពីការសរសេរគម្រោង និងគណនេយ្យទូទៅ។

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីវេទិកាយុវជនអន្តរជាតិ នៅប្រទេសរុស្ស៊ី និង០២រូបទៀត ចូលរួមវគ្គកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រង និងកិច្ចសហប្រតិបត្តិការក្នុងការពង្រឹង

លើវិស័យមីក្រូហិរញ្ញវត្ថុ នៅប្រទេសម៉ាឡេស៊ី ។

-អាហារូបករណ៍ថ្នាក់បណ្ឌិតផ្នែក ការគ្រប់គ្រងរដ្ឋបាលសាធារណៈ ចំនួន០១នាក់ នៅប្រទេសចិន និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក Global ICT Convergence with Management and Public Policy ចំនួន០១នាក់ នៅសាធារណរដ្ឋកូរ៉េ ។

**៨.ការអភិវឌ្ឍស្ថាប័នៈ**

-រដ្ឋាភិបាលចិនយល់ព្រមសាងសង់អគារ១ខ្នង ជូនព្រឹទ្ធសភា (ការប្តូរលិខិតប្តូរសារជាផ្លូវការ) ។

-រដ្ឋសភាវៀតណាមកំពុងសិក្សាអំពីការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងព្រឹទ្ធសភាកម្ពុជា (ការសិក្សាបច្ចេកទេសជាមួយក្រុមហ៊ុនEZECOM ) ។

-ត្រៀមអគារសំរាប់គណៈកម្មការទី១០ ព្រឹទ្ធសភា ។

**៩. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែងៈ**

-ប្រជុំពិនិត្យ និងពិភាក្សាអំពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភារយៈពេល១០ឆ្នាំ(២០១៤-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៤-២០២៤) ។

-ប្រជុំកំណត់គម្រោងថវិកាឆ្នាំ២០១៥ របស់ព្រឹទ្ធសភា ជាមួយនឹងថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ប្រជុំពិនិត្យលើសំណើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ ។

-ប្រជុំពិនិត្យ និងឆ្លងឯកសារស្តីពីសេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ ។

-ធ្វើតេស្តមន្ត្រីរាជការ ត្រៀមតាំងស៊ប់ក្នុងមុខតំណែង ។

-ធ្វើសេចក្តីសម្រេច ស្តីពីគោលនយោបាយចំពោះអ្នករាជការ ដែលបានសុំលាឈប់ពីក្របខ័ណ្ឌអ្នករាជការនៃអគ្គលេខាធិការដ្ឋាន ។

-បានផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់មត្តេយ្យ៥០% សិក្សានៅ AEC អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ១០០%ចំនួន១០កន្លែង នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វគ្គបណ្តុះបណ្តាលរយៈពេលខ្លីចំនួន០៤វគ្គ នៅមជ្ឈមណ្ឌលអាយខន ។

-រៀបចំទីកន្លែងប្រជុំរវាងក្រុមការងារគណបក្សប្រជាជន និងគណបក្ស សម រង្ស៊ី ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១៤លើក ។

-ថតចម្លងឯកសារ ចំនួន១៦៣សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៤៤ក្បាល ដោះស្រាយ

សំណើថវិកា ចំនួន២៩២សំណើ និងសម្ភារចំនួន៥៣សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន ១១៧លើក ។

-ប្រគល់កុំព្យូទ័រលើតុ ម៉ាស៊ីនព្រីនធ័រ ទូដាក់ឯកសារ ចំនួន០៥គ្រឿង និងបិទលេខកូដតុដែក ទូដែកដាក់ឯកសារ បំពង់ទឹកក្តៅ តុអ៊ីណុក កុំព្យូទ័រលើតុ UPS ចំនួន១៨គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ទ្វារបន្ទប់ទឹក ទូរស័ព្ទ ប្តូរអំពូល ព្រី កុងតាក់ កញ្ចក់ទ្វារ កញ្ចក់តុ និងបំពាក់ដៃទ្វារអ៊ីណុក ទ្វារអូតូ ចំនួន៨៩គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៥១គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៤២ ប្រធានបទ ។

**II.ទិសដៅការងារខែកញ្ញា ឆ្នាំ២០១៤**

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា (ការបោះឆ្នោតជ្រើសរើសសមាសភាពគណៈកម្មការ និងសមាជិកក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយ) ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន៖

-ទស្សនកិច្ចសិក្សានៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ (ខែកញ្ញា២០១៤) ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ជំរុញលើកកម្ពស់ចំណេះដឹង ជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

**៦.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ដោះស្រាយការប្រឈមថ្មីៗ លេចចេញពីការដំណោះស្រាយនយោបាយ (ការបង្កើតគណៈកម្មការទី១០, ទីកន្លែង /លេខាធិការដ្ឋាន, មធ្យោបាយ និងធនធាន, តួនាទី ភារកិច្ចរបស់គណៈកម្មការទី១០ អគារថ្មី១ខ្នង សំរាប់បំពេញតំរូវការ ) ។

-បន្តតាមដានគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ដែលត្រូវឆ្លងគណៈរដ្ឋមន្ត្រី និងរដ្ឋសភា ។

-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់០៤អង្គភាព ជាជំហានដំបូង ។

-បន្តពង្រឹងដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

-គិតគូរអំពីការប្រលងផ្ទេរក្របខ័ណ្ឌ ការតាំងស៊ប់ក្នុងមុខតំណែង ការផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ ។ ការបំពេញបន្ថែមតំរូវការរបស់អគ្គនាយកដ្ឋានសេវាច្បាប់/សមូហភាពដែនដី ។

-ត្រៀមការបោះពុម្ពជំណាច់ឆ្នាំ និងរៀបចំប្រទីប ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារ និងទិន្នន័យបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីពង្រឹងសមត្ថភាពការងារ ។

-តាមដានកំណែទំរង់រដ្ឋបាលសាធារណៈដើម្បីកែសំរួលច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ

- "ក" មាន១៤+១០+៦ ថ្នាក់ត្រូវកែមក១៤ថ្នាក់
- "ខ" មាន១៤+១០+៦ ថ្នាក់ត្រូវកែមក១៤ថ្នាក់
- "គ" មាន១៤+១០+៦ ថ្នាក់ត្រូវកែមក១០ថ្នាក់
- "ឃ" លុបចោល ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មការពិសេសគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គលើកទី៥ ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីស្នើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងពិនិត្យ សម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយតំណាងព្រឹទ្ធសភា ជាពិសេសការរៀបចំទីកន្លែងសំរាប់ជំនួបក្រុមការងាររវាងគណបក្សប្រជាជនកម្ពុជា និងគណបក្ស សម រង្ស៊ី ដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ស្របតាមកិច្ចព្រមព្រៀងដំណោះស្រាយនយោយកាលពី ថ្ងៃទី២២ ខែកក្កដាឆ្នាំ២០១៤ ។ ការអនុវត្តនូវដំណោះស្រាយនយោបាយ នឹងបង្កើតឡើងនូវការប្រែប្រួលថ្មី ដែលពាក់ព័ន្ធនឹងសមាសភាពគណៈកម្មការនានារបស់ព្រឹទ្ធសភាផងដែរ ។ នោះគឺបន្ទុកថ្មីបន្ថែមដែលឲ្យទិដ្ឋភាពការងារខុសឆ្ងាយពីនីតិកាលទី១ និងនីតិកាលទី២ ដែលមានត្រឹមតែ៩គណៈកម្មការ ។

ព្រឹទ្ធសភាបានធ្វើការងារអន្តរជាតិប្រកបដោយលទ្ធផលល្អ : បដិសណ្ឋារកិច្ចគណៈប្រតិភូអនុប្រធានព្រឹទ្ធសភាជប៉ុន និងដំណើរទស្សនកិច្ចរបស់គណៈកម្មការទី៥ទៅចិន ដែលផ្តល់លទ្ធភាពដល់ជំនួយថ្មីពីប្រភពជប៉ុន និងចិន ។

ជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន បានយកចិត្តទុកដាក់ខ្ពស់ក្នុងការប្រជុំពិនិត្យ និងកែសម្រួលក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន (២០១៨-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៨-២០២៤) ព្រមទាំងធ្វើតេស្តមន្ត្រីរាជការត្រៀមតាំងស៊ប់ក្នុងមុខតំណែង និងបន្តពិចារណាអំពីនីតិវិធីអនុវត្តបទបញ្ជាផ្ទៃក្នុងដែលតំរង់ទិសកំណែទំរង់កិច្ចការសភានាពេលខាងមុខ ។ Th

ភ្នំពេញ,ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

**អគ្គលេខាធិការស្តីទី**

**ឡោក_ឆាយ**